# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

**ចំណេះដឹងទូទៅ**
**(General Knowledge)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : បួនចំនុចដែលអ្នកត្រូវអនុវត្តដើម្បីរួចផុតពីការបោកប្រាស់
កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ១៦ មេសា ២០១២
ចែករំលែកចំណេះដឹងដោយ (Knowledge shared by) : លោក សៀង ប៊ូហឿង

## ១. សេចក្តីផ្តើម (Introduction)

ជាទូទៅការបោកប្រាស់ គឺជាទង្វើរមួយដែលត្រូវបានសង្គមស្អប់ខ្ពើម ។ យ៉ាងណាក៏ដោយ ការបោកប្រាស់នៅតែអាចកើតមានឡើង ទោះជានៅក្នុងប្រទេសជឿនលឿនដែលបានអភិវឌ្ឍរួចហើយក៏ដោយ ។ ការរួចផុតពីការបោកប្រាស់ មានន័យថាមិនបានទទួលរងការខាតបង់ទាំងឡាយណាដែលបង្ករឡើងដោយជនទុច្ចរិតណាមួយនោះទេ ។ ការខាតបង់ទាំងនោះរួមមានដូចជាការខាតបង់ទ្រព្យសម្បត្តិ ការខាតបង់ពេលវេលា ការខាតបង់គំនិត ការខាតបង់សាច់ញាតិឬអ្នកដែលគាំទ្ររបស់អ្នក ការខាតបង់កាយសម្បទាឬអាយុជីវិត ...។ល។

## ២. ការយល់ដឹង (Knowledge)

ខ្ញុំបាទសូមលើកឡើងអំពី "បួនចំនុចដែលអ្នកត្រូវអនុវត្តដើម្បីរួចផុតពីការបោកប្រាស់" ៖

-**ការគ្រប់គ្រងភាពមានមហិច្ឆិតារបស់ខ្លួន** : ការបោកប្រាស់ អាចនឹងផ្តើមចេញពីការដុតភ្លើងមហិច្ឆិតារបស់អ្នក ។ ដូច្នេះអ្នកត្រូវចេះគ្រប់គ្រងភាពមានមហិច្ឆិតារបស់អ្នក ដោយព្យាយាមមិនអោយគេដឹងច្បាស់ពីមហិច្ឆិតារបស់អ្នក និងមិនត្រូវអោយមហិច្ឆិតារបស់អ្នកជំរុញអោយអ្នកធ្វើការសម្រេចចិត្តដោយគ្មានការពិចារណាអោយបានល្អិតល្អន់ ។ ជាឧទាហរណ៏នៃភាពមានមហិច្ឆិតា រួមមានដូចជា អ្នកចង់ក្លាយជាអ្នកមានក្នុងពេលឆាប់ៗ អ្នកចង់ទៅរស់នៅឯសហរដ្ឋអាមេរិក អ្នកចង់ទៅធ្វើការនៅបរទេស អ្នកចង់បានសង្សារជាអ្នកមាន អ្នកចង់ក្លាយជាមនុស្សល្បីល្បាយ ...។ល។

-**កាគ្រប់គ្រងភាពមានមេត្តាធិមរបស់ខ្លួន** : មេត្តាធិមជាអ្វីដែលសង្គមចង់បាន និងជាអ្វីដែលអ្នករាល់គ្នាចង់បានផងដែរ ប៉ុន្តែអ្នកក៏ត្រូវចេះមានការប្រុងប្រយ័ត្ន ក៏ដូចជាការគ្រប់គ្រងភាពមានមេត្តាធិមរបស់ខ្លួន។ ជារួមត្រូវធ្វើការពិចារណថាតើអ្នកណាគួរអោយអាណិតនិងគួរអោយអ្នកជួយ អ្នកណាគួរអោយអាណិតប៉ុន្តែមិនគួរអោយអ្នកជួយ អ្នកណាមិនគួរអោយ

អាណិតនិងមិនគួរអោយអ្នកជួយ  អ្នកណាមិនគួរអោយអាណិតប៉ុន្តែគួរអោយអ្នកជួយ  ដើម្បីចៀសផុតពីការទទួលរងការបោកប្រាស់ និងការលើកស្ទួយនូវការបោកប្រាស់ដោយមិនដឹងខ្លួន។

-**ភាពវៃឆ្លាត និងយល់ដឹងពីបរិបទជុំវិញ** : សំដៅទៅលើភាពអាចយល់បាន និងអាចសន្និដ្ឋានបានចំពោះទង្វើរបោកប្រាស់ទាំងនោះ ដោយផ្អែកលើបទពិសោធន៏ (បទពិសោធន៏ផ្ទាល់ និងបទពិសោធន៏ប្រយោល) ក៏ដូចជាភាពវៃឆ្លាតរបស់អ្នក ហើយក៏សំដៅទៅលើភាពអាចយល់បាន និងអាចសន្និដ្ឋានបានចំពោះទង្វើរបោកប្រាស់បែបប្រយោល ជាឧទាហរណ៏ដូចជា "សុភាព" ជាមិត្តភ័ក្តិជិតស្និត ជឿជាក់ និងស្មោះត្រង់របស់អ្នក ហើយដោយភាពមិនសូវឆ្លាត ធ្វើអោយ "សុភាព" ចាញ់បោកគេដោយមិនដឹងខ្លួន បន្ទាប់មកទៀត "សុភាព" ក៏អាចមកបោកប្រាស់អ្នកបន្តដោយមិនដឹងខ្លួនផងដែរ ។

-**ការហ៊ានទំលាយអំពីរឿងចាញ់បោកគេ** : ជាទូទៅអ្នកដែលចាញ់បោកគេ មិនហ៊ាននិយាយចេញមកក្រៅទេ ពីព្រោះក្លាចខ្មាស់គេ ឬក្លាចគេសើចចំអក ដែលទង្វើរបែបនេះធ្វើអោយជនបោកប្រាស់កាន់តែបានចិត្ត ។ ផ្ទុយទៅវិញ បើអ្នកបង្ហាញអោយឃើញនូវការហ៊ានទំលាយអំពីរឿងចាញ់បោកគេ នោះវាអាចជារឿងមួយដែលធ្វើអោយជនបោកប្រាស់មិនហ៊ាន ឬស្ទាក់ស្ទើក្នុងការបោកប្រាស់អ្នក ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកត្រូវធ្វើការសម្រេចចិត្តអោយបានច្បាស់ថាតើអ្នកគួរប្រាប់ពីរឿងចាញ់បោកគេនេះ ទៅនរណាដែលអាចជាប្រយោជន៏ក្នុងការជួយដល់អ្នកបាន ។

## ៣. ការផ្តល់អនុសាសន៏ (Recommendation)

ការលើកឡើងខាងលើ វាគ្រាន់តែជាការលើកឡើងដោយសង្ខេប និងការយល់ឃើញផ្ទាល់ខ្លួនរបស់ខ្ញុំបាទតែប៉ុណ្ណេះ ។ វាក៏អាចជាចំណេះដឹងទូទៅមួយសម្រាប់អ្នកក្នុងការពិចារណាអនុវត្តតាម ដើម្បីរួចផុតពីការបោកប្រាស់។ ម្យ៉ាងវិញទៀតចូរកត់សំគាល់ថាជនបោកកប្រាស់ជារឿយៗ ទុកពេលវេលាអោយអ្នកយ៉ាងខ្លីបំផុតក្នុងការសម្រេចចិត្ត ដើម្បីកុំអោយអ្នកមានពេលពិចារណាច្រើន ឬសុំជំនួយពីគ្រោះយោលប់ពីអ្នកដ៏ទៃ ។ ហើយជនបោកប្រាស់ ក៏អាចធ្វើសកម្មភាពជាក្រុមដោយមានតួសំដែងជាច្រើន ដូចក្នុងរឿងវីដេអូអញ្ជឹង ដែលនឹងសំដែងយ៉ាងសមបំផុត។